**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ៖ បព ១២៥/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# កិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋតូហ្គោ

**ឯកឧត្តម ស្មាន ម៉ាណាន** រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង**ឯកឧត្តម** Afognon Kouakou SEDAMINOU អគ្គលេខាធិការក្រសួងការបរទេស សហប្រតិបត្តិការ សមាហរណកម្មអាហ្វ្រិក និងប្រជាជនតូហ្គោនៅក្រៅប្រទេសនៃសាធារណរដ្ឋតូហ្គោ បានដឹកនាំ**កិច្ចពិគ្រោះយោបល់ទ្វេភាគីលើកទី១** រវាងក្រសួងទាំងពីរ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី៣-៤ ខែកញ្ញា ឆ្នាំ២០២៦ នៅទីក្រុងឡូម៉េ ប្រទេសតូហ្គោ។

ភាគីទាំងពីរបានសម្តែងការសាទរចំពោះសន្ទុះជាវិជ្ជមាននៃទំនាក់ទំនងទ្វេភាគី និងបានពិចារណាពីវិធីសាស្ត្រដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការនៅក្នុងវិស័យ**ពាណិជ្ជកម្ម និងវិនិយោគ កសិកម្ម ទេសចរណ៍ ការតភ្ជាប់ផ្លូវអាកាស និងកិច្ចសហប្រតិបត្តិការសភា**។

គណៈប្រតិភូកម្ពុជាក៏បានជួបពិភាក្សាប្រកបដោយផ្លែផ្កាជាមួយ **ឯកឧត្តម** Badanam PATOKI រដ្ឋមន្ត្រីសេដ្ឋកិច្ច និងត្រួតពិនិត្យយុទ្ធសាស្ត្រ, **ឯកឧត្តម** Edem Kokou TENGUE រដ្ឋមន្ត្រីប្រតិភូទទួលបន្ទុកសេដ្ឋកិច្ចសមុទ្រ និងជាអគ្គនាយកកំពង់ផែស្វយ័តឡូមេ និងលោក Konlani Djondiègue នាយកខុទ្ទកាល័យក្រសួងកសិកម្ម នេសាទ ធនធានសត្វ និងអធិបតេយ្យភាពស្បៀងអាហារ។

ភាគីតូហ្គោបានបញ្ជាក់ជាថ្មីអំពីការចូលរួមរបស់ **ឯកឧត្តម** Faure Essozimna Gnassingbé **ប្រធានាធិបតី** ក្នុងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅរាជធានីភ្នំពេញ។ ភាគីកម្ពុជាក៏បានលើកទឹកចិត្តតូហ្គោ ចូលរួមក្នុងព្រឹត្តិការណ៍អមកិច្ចប្រជុំកំពូលផងដែរ រួមមានព្រឹត្តិការណ៍បច្ចេកវិទ្យា FrancoTech (ថ្ងៃទី**១៥–១៦ ខែវិច្ឆិកា**) និងភូមិហ្វ្រង់កូហ្វូនី (ថ្ងៃទី**១៣–១៧ វិច្ឆិកា** ២០២៦)។

កិច្ចពិគ្រោះយោបល់នេះ ត្រូវបានរៀបចំឡើងដោយអនុលោមតាម**អនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចពិគ្រោះយោបល់ទ្វេភាគីកម្ពុជា-តូហ្គោ** ដែលត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីការបរទេសនៃប្រទេសទាំងពីរ កាលពីថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០២៥ កន្លងទៅនេះ៕

ថ្ងៃអង្គារ ១១រោច ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២៦

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh